បេឡាជាតិសន្តិសុខសង្គម
National Social Security Fund

# ព្រឹត្តិបត្រព័ត៌មានបេឡាជាតិសន្តិសុខសង្គម

ប.ស.ស. ឆ្នាំទី ១២
លេខ ៣១ ឆ្នាំ ២០២១



ប.ស.ស. ហានិភ័យការងារ

ប.ស.ស. ថែទាំសុខភាព

ប.ស.ស. ប្រាក់សោធន

ធានាសន្តិសុខប្រាក់ចំណូល  រួមចំណែកកាត់បន្ថយភាពក្រីក្រ  លើកកម្ពស់ស្ថិរភាពសង្គម

# ព្រឹត្តិបត្រព័ត៌មាន ប.ស.ស.




## មាតិកា


០១ ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. បើកកិច្ចប្រជុំត្រួតពិនិត្យ និង..........១
០២ ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. បើកកិច្ចប្រជុំលើកទី៦..................៤
០៣ ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. បើកកិច្ចប្រជុំអាណត្តិទី១...............៦
០៤ ឯកឧត្តម អ៊ុក សមវិទ្យា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា..........៨
០៥ ក្រុមការងារបច្ចេកទេសនៃ ប.ស.ស. ប្រជុំពិភាក្សាត្រួតពិនិត្យ.......១០
០៦ សេចក្ដីព្រាងអនុក្រឹត្យស្ដីពី ការបង្កើតក្រុមប្រឹក្សាវេជ្ជសាស្ត្រ នៃ.... ១២
០៧ អគ្គនាយក ប.ស.ស. ធ្វើបាឋកថាស្ដីពី តួនាទី និងភារកិច្ចរបស់.....១៤
០៨ ឯកឧត្តម អ៊ុក សមវិទ្យា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា.........១៦
០៩ អគ្គនាយក ប.ស.ស. ផ្ដល់កិត្តិយសអញ្ជើញចូលរួមប្រជុំពិភាក្សា...១៨
១០ ប.ស.ស. កម្ពុជា ចូលរួមមហាសន្និបាតលើកទី៥ នៃសមាគម......២០
១១ ប.ស.ស. កម្ពុជា ចូលរួមសន្និសីទសកលស្ដីពី ការធ្វើឲ្យប្រសើរ...២៣
១២ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម ធ្វើបទបង្ហាញស្ដីពី........... ២៥
១៣ ក្នុងបរិបទដ៏លំបាក នៃសម័យកាលជំងឺកូវីដ-១៩ .....................២៧
១៤ ប.ស.ស. ចុះអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយ......... ២៩
១៥ ប.ស.ស. បាននឹងកំពុងពន្លឿនការអភិវឌ្ឍមជ្ឈមណ្ឌលព័ត៌មាន....៣២
១៦ ក្រុមការងារបច្ចេកទេសនៃ ប.ស.ស. ជួបពិភាក្សាការងារ............៣៤
១៧ វគ្គបណ្ដុះបណ្ដាលស្ដីពី "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន....៣៥
១៨ ថ្នាក់ដឹកនាំ ប.ស.ស. ចូលរួមកិច្ចពិភាក្សាស៊ីជម្រៅជាមួយ...........៣៧
១៩ សមាជិក ប.ស.ស. ជាកម្មករនិយោជិតនៃវិស័យឯកជន នឹង.......៣៩
២០ ក្រុមការងារ ស.ផ.ក នៃ ប.ស.ស. ប្រជុំពិភាក្សាត្រួតពិនិត្យ.........៤១
២១ តំណាងអង្គការជាតិ និងអន្តរជាតិ សរុបប្រមាណជាង ១០០.......៤៣
២២ ដើម្បីឲ្យថ្លើមមានសុខភាពល្អ អ្នកគួរតែជ្រើសយកអាហារ............៤៥
២៣ បណ្ដាំ អ្នកព្រះភិរម្យភាសា អ៊ូ ហៅង៉ុយ.....................................៤៦








**រចនាសម្ព័ន្ធព្រឹត្តិបត្រ**

**ឯកឧត្តម អ៊ុក សមវិទ្យា**
**អគ្គនាយក ប.ស.ស.**

| | |
|---|---|
| **ចាងហ្វាង** | ឯកឧត្តម **ហេង សុផាន់ណារិទ្ធ** |
| **និពន្ធនាយក** | លោក **អ៊ុក សំអូន** |
| **និពន្ធនាយករង** | លោកស្រី **ចាន់ ស៊ីណូន** |
| | លោក **ឃុន វិចិត្រ** |
| | លោក **វ៉ាន់ ចាន់ថន** |
| **លេខានិពន្ធ** | លោក **នាង ជូ** |
| | លោក **យន គន្ធា** |
| | លោក **អ៊ឹង លាងឆុង** |
| | លោក **យង់ សុខន** |
| **ផ្នែកការីកុំព្យូទ័រ** | លោក **អ៊ុង ស៊ីខឿ** |
| | លោក **តួង គីមលាង** |
| | លោក **ថេត ពិសិដ្ឋ** |




# ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. បើកកិច្ចប្រជុំត្រួតពិនិត្យ និងពិភាក្សាលើរបាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០២០ របស់បេឡាជាតិសន្តិសុខសង្គម ប.ស.ស.

ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នាថ្ងៃចន្ទ ទី១៨ ខែមករា ឆ្នាំ២០២១ ក្រុមប្រឹក្សា-ភិបាលនៃ ប.ស.ស. បានដំណើរការនៃកិច្ចប្រជុំលើកទី៥ អាណត្តិទី១ របស់ខ្លួនក្នុងការពិនិត្យពិភាក្សាលើរបាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០២០ បន្ទាប់ពីបានបើកកិច្ចប្រជុំពិភាក្សាចំនួន ៤លើករួចមកហើយ និងបានសម្រេចអនុម័តទាក់ទងទៅនឹងរបៀបវារៈមួយចំនួនដូចខាងក្រោម៖

- អនុក្រឹត្យ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃបេឡាជាតិសន្តិសុខសង្គម និង-បទបញ្ជាផ្ទៃក្នុងរបស់បេឡាជាតិសន្តិសុខសង្គម
- សេចក្តីសម្រេចស្តីពី បែបបទ និងនីតិវិធីនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គម
- អនុក្រឹត្យ ស្តីពី របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ
- សេចក្តីសម្រេច ស្តីពីលក្ខន្តិកៈបុគ្គលិកនៃបេឡាជាតិសន្តិសុខសង្គម
- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់ប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ភាគទាន។

សូមបញ្ជាក់ថា យោងតាមមាត្រា៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ បានចែងថា ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. មានបេសកកម្មដឹកនាំ តម្រង់ទិសការអនុវត្តសកម្មភាពការងារ និងធ្វើការត្រួត





ពិនិត្យលើដំណើរការរបស់ ប.ស.ស. ដោយផ្តោតពិសេសលើការត្រួតពិនិត្យ និងអនុម័តផែនការអភិវឌ្ឍរបស់ ប.ស.ស. សម្រាប់រយៈពេលមធ្យមនិងរយៈពេលវែង ការអនុម័តគម្រោងថវិកា និងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ ប.ស.ស. ការត្រួតពិនិត្យ និងអនុម័តរបាយការណ៍គ្រប់គ្រង ប.ស.ស. និងការត្រួតពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុជាដើម។

ក្រោមការចង្អុលបង្ហាញ និងតម្រង់ទិសលើការអនុវត្តសកម្មភាពការងារ ពីសំណាក់ក្រុមប្រឹក្សាភិបាលតាំងពីដើមរហូតមកដល់ពេលនេះ បេឡាជាតិសន្តិសុខសង្គម សម្រេចបាននូវលទ្ធផលផ្លែផ្កាជាច្រើន ស្របទៅតាមគោលនយោបាយជាតិគាំពារសង្គមកម្ពុជា។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ទំនុកចិត្ត និងប្រគល់ភារកិច្ចដល់ស្ថាប័នមួយនេះ ជាប្រតិបត្តិករតែមួយគត់ក្នុងការផ្តល់សេវារបបសន្តិសុខសង្គមជូនបងប្អូនកម្មករនិយោជិតផងដែរ ។

**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានស្នើដល់សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវបន្តពិភាក្សាឲ្យបានគ្រប់ជ្រុងជ្រោយបន្ថែមទៀត ដើម្បីឲ្យច្បាប់ស្តីពីរបបសន្តិសុខសង្គមនេះ កាន់តែមានលក្ខណៈល្អឡើងធ្វើយ៉ាងណាឲ្យការអនុវត្តតាមគោលការណ៍នានារបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាធានាបាននូវសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋពិសេសបងប្អូនកម្មករនិយោជិត ប្រកបដោយចីរភាព។











គួរឲ្យដឹងផងដែរថា បច្ចុប្បន្ន បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បាននឹងកំពុងអនុវត្តរបបសន្តិសុខសង្គមចំនួន២ គឺ៖

១.របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ) ចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០០៨

២.របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០១៦ ហើយនៅពេលដ៏ខ្លីខាងមុខនេះ ប.ស.ស. នឹងដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនផងដែរ។ រហូតមកទាល់ពេលនេះ ប.ស.ស. មានសមាជិកសរុបប្រមាណជាង ២លាននាក់ហើយ ដែលកំពុងប្រើប្រាស់សេវា និងទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គមពី ប.ស.ស.។

សូមបញ្ជាក់ថា កិច្ចប្រជុំពិភាក្សាខាងលើ ប្រព្រឹត្តទៅនៅសាលប្រជុំក្រុមប្រឹក្សាភិបាលនៃទីស្នាក់ការកណ្តាលបេឡាជាតិសន្តិសុខសង្គម រាជធានីភ្នំពេញ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់សមាជិកនៃក្រុមប្រឹក្សាភិបាលចំនួន ១១រូប៕











# ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. បើកកិច្ចប្រជុំលើកទី៦ អាណត្តិទី១ ក្នុងការពិភាក្សាត្រួតពិនិត្យ អនុម័តសម្រេច លើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រ នៃបេឡាជាតិសន្តិសុខសង្គម

កិច្ចប្រជុំពិភាក្សាត្រួតពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតក្រុមប្រឹក្សាវេជ្ជសាស្ត្រ នៃបេឡាជាតិសន្តិសុខសង្គម ប្រព្រឹត្តទៅនាថ្ងៃព្រហស្បតិ៍ ទី១៨ ខែមីនា ឆ្នាំ២០២១ នេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម។

ថ្លែងទៅកាន់អង្គប្រជុំ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** បានស្នើដល់សមាជិកក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ទាំងអស់ត្រូវយកចិត្តទុកដាក់ឲ្យបានខ្ពស់ក្នុងការពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាពនៃការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. និងដើម្បីកំណត់អំពីការបាត់បង់សមត្ថភាពការងារ ស្ថានភាពទុព្វលភាពរបស់សមាជិក ប.ស.ស. ឲ្យមានលក្ខណៈច្បាស់លាស់ត្រឹមត្រូវនិងមានលក្ខណៈល្អប្រសើរឡើង ធ្វើយ៉ាងណាឲ្យការអនុវត្តនេះ ស្របតាមគោលការណ៍នានារបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ធានាបាននូវសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត ប្រកបដោយចីរភាព។

យោងតាមមាត្រា៤៧ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម បានចែងថា ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស. មានតួនាទីត្រួតពិនិត្យ តាមដាន ការអនុវត្តកិច្ចព្រមព្រៀងរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.







ហើយការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស. នេះ គឺត្រូវកំណត់ដោយអនុក្រឹត្យ។

ជាមួយគ្នានេះ **ឯកឧត្តមបណ្ឌិត រដ្ឋមន្ត្រី** ថ្លែងកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ ប.ស.ស. រហូតមកដល់ពេលនេះ បើទោះបីស្ថិតក្នុងស្ថានភាពដ៏លំបាកយ៉ាងណាក្តី បេឡាជាតិសន្តិសុខសង្គមនៅតែបំពេញតួនាទីយ៉ាងសំខាន់ក្នុងការបម្រើអត្ថប្រយោជន៍របបសន្តិសុខសង្គមជូនដល់សមាជិករបស់ខ្លួន ជារៀងរាល់ថ្ងៃប្រកបដោយស្មារតីទទួលខុសត្រូវ និងតាមវិធានរបស់ក្រសួងសុខាភិបាលក្នុងន័យរួមចំណែកទប់ស្កាត់នៃជំងឺកូវីដ-១៩ ឆ្លើយតបទៅនឹងអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខដឹកនាំនៃកម្ពុជា តែងតែគិតគូរ និងខ្វាយខ្វល់បំផុតអំពីសុខុមាលភាព និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត ។

សូមបញ្ជាក់ថា កិច្ចប្រជុំពិភាក្សាខាងលើ ប្រព្រឹត្តទៅនៅទីស្តីការក្រសួង-ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់សមាជិកនៃក្រុមប្រឹក្សាភិបាលចំនួន ១០រូប តាមប្រព័ន្ធវីដេអូ (Video Conference) ៕








# ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. បើកកិច្ចប្រជុំអាណត្តិទី១ លើកទី៧ ទៅតាមកម្មវិធីដែលបានគ្រោងទុក

នៅថ្ងៃចន្ទ ទី២ ខែសីហា ឆ្នាំ២០២១ នេះ ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. បានបើកកិច្ចប្រជុំអាណត្តិទី១ លើកទី៧ របស់ខ្លួន ទៅតាមកម្មវិធីដែលបានគ្រោងទុក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីសំណាក់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បន្ទាប់ពីបានពិភាក្សាត្រួតពិនិត្យ អនុម័តសម្រេចលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រ នៃ ប.ស.ស. កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ កន្លងមក។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. ផ្តោតទៅលើរបៀបវារៈសំខាន់ៗដូចខាងក្រោម៖

១.សេចក្តីព្រាងផែនការថវិកាឆ្នាំ ២០២២ របស់បេឡាជាតិសន្តិសុខសង្គម(ប.ស.ស.)

២.សំណើសុំគោលការណ៍ពិនិត្យលទ្ធភាពកែសម្រួលអត្រាភាគទានសម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

៣.បញ្ហាផ្សេងៗ។








ថ្លែងទៅកាន់អង្គប្រជុំ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** បានស្នើដល់សមាជិកក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ទាំងអស់ត្រូវយកចិត្តទុកដាក់ឲ្យបានខ្ពស់ក្នុងការពិភាក្សាឲ្យបានផុសផុល និងស៊ីជម្រៅលើរបៀបវារៈសំខាន់ៗខាងលើ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព នៃការរៀបចំផែនការថវិកាក៏ដូចជាប្រសិទ្ធភាពនៃការកែសម្រួលអត្រាភាគទានសម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឲ្យកាន់តែមានភាពល្អប្រសើរ ត្រឹមត្រូវ និងច្បាស់លាស់ឆ្លើយតបទៅនឹងគោលនយោបាយជាតិគាំពារសង្គមកម្ពុជា។

ជាមួយគ្នានេះ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ ប.ស.ស. រហូតមកដល់ពេលនេះ បើទោះបីស្ថិតក្នុងស្ថានភាពដ៏លំបាកនៃការរីករាលដាលនៃជំងឺកូវីដ-១៩ យ៉ាងណាក្តី បេឡាជាតិសន្តិសុខសង្គម នៅតែបំពេញតួនាទីយ៉ាងសំខាន់ក្នុងការបម្រើអត្ថប្រយោជន៍របបសន្តិសុខសង្គម ជូនដល់សមាជិករបស់ខ្លួន ជារៀងរាល់ថ្ងៃ ប្រកបដោយស្មារតីទទួលខុសត្រូវ និងតាមវិធានរបស់ក្រសួងសុខាភិបាល ក្នុងន័យរួមចំណែកទប់ស្កាត់នៃជំងឺកូវីដ-១៩ ឆ្លើយតបទៅនឹងអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខដឹកនាំនៃកម្ពុជា តែងតែគិតគូរ និងខ្វាយខ្វល់បំផុត អំពីសុខុមាលភាព និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត ។

សូមបញ្ជាក់ថា កិច្ចប្រជុំពិភាក្សាខាងលើប្រព្រឹត្តទៅនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់សមាជិកនៃក្រុមប្រឹក្សាភិបាលចំនួន ១០រូប តាមប្រព័ន្ធវីដេអូ (Zoom Meeting) ៕











# ឯកឧត្តម អ៊ុក សមវិទ្យា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម ផ្តល់កិត្តិយសអញ្ជើញចូលរួមឈ្វេងយល់ក្នុងវគ្គបណ្តុះបណ្តាលមួយតាមរយៈប្រព័ន្ធវីដេអូ

ក្នុងឱកាសអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីអភិបាលកិច្ច និងការគ្រប់គ្រងការវិនិយោគ និងទិន្នន័យសម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ នៃរបបសន្តិសុខសង្គម នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ នេះ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម បានថ្លែងថា ក្នុងនាមថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ និងបុគ្គលិកទាំងអស់នៃ ប.ស.ស. ពិតជារីករាយ និងស្វាគមន៍ចំពោះការរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់មួយនេះឡើង។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលនេះ វាពិតជាសំខាន់ណាស់ក្នុងការអភិវឌ្ឍសមត្ថភាពជំនាញលើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ការគ្រប់គ្រងការវិនិយោគ និង















ទិន្នន័យសម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ នៃរបបសន្តិសុខសង្គមកម្ពុជា ដើម្បីជាទុនមួយសម្រាប់ការគ្រប់គ្រងរៀបចំរចនាសម្ព័ន្ធវិនិយោគ លើដំណើរការអភិវឌ្ឍវិស័យរបបសន្តិសុខសង្គម ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ឆ្លើយតបទៅនឹងការណែនាំរបស់ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្តារសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋក្នុងសម័យកាលជំងឺកូវីដ-១៩។

ជាមួយនឹងការបណ្តុះបណ្តាលពីអ្នកជំនាញការមកពីអង្គការអន្តរជាតិខាងការងារ(ILO)និងអ្នកជំនាញការមកពីកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) **ឯកឧត្តមប្រតិភូ** បានស្នើដល់ថ្នាក់ដឹកនាំព្រមទាំងមន្ត្រីជំនាញនៃ ប.ស.ស. ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ត្រូវយកចិត្តទុកដាក់សិក្សាឈ្វេងយល់ ដើម្បីពង្រឹងសមត្ថភាពចំណេះជំនាញឲ្យកាន់តែល្អប្រសើរ ក្នុងការរៀបចំគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងការវិនិយោគ ប្រកបដោយភាពជោគជ័យ ជាពិសេសសមាជិកក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ មេត្តាជួយផ្តល់ជាមតិយោបល់ ដើម្បីទទួលបាននូវធាតុចូលសំខាន់ៗក្នុងការលើកកម្ពស់ឲ្យវគ្គបណ្តុះបណ្តាលមួយនេះកាន់តែមានលក្ខណៈទូលំទូលាយ ស៊ីជម្រៅ ប្រកបដោយប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

**ឯកឧត្តមប្រតិភូ** បានបន្តទៀតថា ការពិតទៅ វគ្គបណ្តុះបណ្តាលនេះ គឺតម្រូវឲ្យសិក្ខាកាម ចូលរួមសិក្សាឈ្វេងយល់ដោយផ្ទាល់ ក៏ប៉ុន្តែដោយសារជំងឺកូវីដ-១៩ នៅតែបន្តរីករាលដាល និងដើម្បីរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គល តាមការណែនាំរបស់រាជរដ្ឋាភិបាលតាមរយៈក្រសួងសុខាភិបាល យើងត្រូវសិក្សាតាមរយៈប្រព័ន្ធវីដេអូវិញ។

សូមបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលខាងលើប្រព្រឹត្តទៅចំនួន ២វគ្គ ដែលវគ្គទី១ ចាប់ពីថ្ងៃទី១២ ដល់ទី១៣ ខែមករា ឆ្នាំ២០២១ និងវគ្គទី២ ចាប់ពីថ្ងៃទី២៦ ដល់ទី២៧ ខែមករា ឆ្នាំ២០២១ ដែលបានរៀបចំឡើងដោយអង្គការអន្តរជាតិខាងការងារ (ILO) និងកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) តាមរយៈប្រព័ន្ធវីដេអូ (Video Conference) នៅសាលប្រជុំធំ ប.ស.ស. រាជធានីភ្នំពេញ ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃ ប.ស.ស. និងក្រុមការងារនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិគាំពារសង្គមជាច្រើននាក់៕







# ក្រុមការងារបច្ចេកទេសនៃ ប.ស.ស. ប្រជុំពិភាក្សាត្រួតពិនិត្យ លើសេចក្តីព្រាង អនុក្រឹត្យ ស្តីពី ការបង្កើតក្រុមប្រឹក្សាវេជ្ជសាស្ត្រ នៃបេឡាជាតិសន្តិសុខសង្គម



កិច្ចប្រជុំពិភាក្សាត្រួតពិនិត្យ លើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃបេឡាជាតិសន្តិសុខសង្គមនេះ ប្រព្រឹត្តទៅនាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៅសាលប្រជុំធំស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

ថ្លែងទៅកាន់អង្គប្រជុំ **ឯកឧត្តម** ប្រតិភូ បានណែនាំដល់ក្រុមការងារបច្ចេកទេសទាំងអស់ត្រូវយកចិត្តទុកដាក់ឲ្យបានខ្ពស់ក្នុងការពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះដើម្បីលើកកម្ពស់គុណភាពប្រសិទ្ធភាព នៃការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. និងដើម្បីកំណត់អំពីការបាត់បង់សមត្ថភាពការងារស្ថានភាពទុព្វលភាព របស់សមាជិក ប.ស.ស. មានលក្ខណៈច្បាស់លាស់មុនដាក់ឆ្លងក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ពិនិត្យអនុម័តសម្រេច ឲ្យស្របទៅតាមគោលនយោបាយជាតិគាំពារសង្គមកម្ពុជា





ក្នុងការផ្ដល់សេវារបបសន្តិសុខ-សង្គមជូនបងប្អូនកម្មករនិយោជិតប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា។

សូមបញ្ជាក់ថា យោងតាមមាត្រា ៤៧ នៃព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ បានចែងថាក្រុមប្រឹក្សាវេជ្ជ-សាស្ត្រនៃ ប.ស.ស. មានតួនាទីត្រួត-ពិនិត្យ តាមដាន ការអនុវត្តកិច្ចព្រមព្រៀងរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ហើយការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស. នេះ គឺត្រូវកំណត់ដោយអនុក្រឹត្យ៕













# សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាវេជ្ជសាស្ត្រ នៃ បេឡាជាតិសន្តិសុខសង្គមត្រូវបានលើកយកមកប្រជុំពិភាក្សាបន្តលើកទី២

សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស. នេះ មានសារសំខាន់ណាស់ទាក់ទងទៅនឹងការអនុវត្តកិច្ចព្រមព្រៀងរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.។

ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម ដោយមានការចូលរួមពីមន្ត្រីជំនាញសំខាន់ៗផងដែរនោះ **ឯកឧត្តមអគ្គនាយក** បានថ្លែងបញ្ជាក់សាជាថ្មីថា ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស. នេះ បង្កើតឡើងមានតួនាទីត្រួតពិនិត្យ តាមដានការអនុវត្តកិច្ចព្រមព្រៀងរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.។



ការបង្កើតឲ្យមានក្រុមប្រឹក្សាវេជ្ជសាស្ត្រខាងលើនេះ ក្នុងគោលដៅដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព នៃកិច្ចព្រមព្រៀង ដែលបានកំណត់អំពីការបាត់បង់សមត្ថភាពការងារ ស្ថានភាពទុព្វលភាពរបស់សមាជិក ប.ស.ស. ឲ្យបានច្បាស់លាស់ ស្របទៅតាមគោលនយោបាយជាតិគាំពារសង្គមកម្ពុជា ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងភាពទាន់ពេលវេលា។





**ឯកឧត្តមអគ្គនាយក** បានបញ្ជាក់ថា កន្លងមកសេចក្តីព្រាងអនុក្រឹត្យខាងលើនេះ ត្រូវបានប្រជុំពិភាក្សា និងកែសម្រួលនូវចំណុចខ្វះខាតមួយចំនួនម្តងរួចមកហើយកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ កន្លងទៅ ហើយឆ្លងកាត់ នៃកិច្ចប្រជុំពិភាក្សាលើកទី២នេះឃើញថា សេចក្តីព្រាងអនុក្រឹត្យនេះមានវិសាលភាពកាន់តែច្បាស់លាស់ល្អប្រសើរជាងមុនដែលអាចដាក់ឆ្លងក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ដើម្បីពិនិត្យ និងអនុម័តសម្រេចនៅពេលខាងមុខបាន។

សូមបញ្ជាក់ថា កិច្ចប្រជុំពិភាក្សាត្រួតពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស. នេះ ប្រព្រឹត្តទៅនាថ្ងៃពុធ ៥រោច ខែផល្គុន ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ នៅសាលប្រជុំធំស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ៕








# អគ្គនាយក ប.ស.ស. ធ្វើបាឋកថាស្ដីពី "តួនាទី និងភារកិច្ចរបស់បេឡាជាតិសន្តិសុខសង្គម" ដល់សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១១ សិស្សមន្ត្រីក្រមការជំនាន់ទី៩ និងកម្មសិក្សាការី នៃសាលាភូមិន្ទរដ្ឋបាល

ក្នុងស្ថានភាពដែលជំងឺកូវីដ-១៩ បានបម្លែងខ្លួន ហើយនឹងកំពុងវាយលុកមកលើពលរដ្ឋទូទាំងពិភពលោក ក៏ដូចនៅកម្ពុជា កាន់តែគួរឲ្យភ័យខ្លាចបំផុតនៅពេលនេះ ប្រមុខដឹកនាំ នៃព្រះរាជាណាចក្រកម្ពុជា ជាបន្តបន្ទាប់បានអំពាវនាវផងអង្វរទទូចផង ដល់ពលរដ្ឋឲ្យប្រយ័ត្ន និងបើគ្មានការចាំបាច់ត្រូវនៅក្នុងផ្ទះ ដើម្បីជៀសផុតពីការឆ្លងនៃជំងឺដ៏កំណាចមួយនេះ ជាមួយគ្នានឹងការអនុវត្ត ៣ការពារ និង៣កុំ ជាប់ជាប្រចាំផងដែរ ។

ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ដោយអនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ពីសំណាក់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា "សម្រាប់មន្ត្រីរាជការបុគ្គលិកក្នុងស្ថាប័នរដ្ឋ ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ទាំងវិស័យសាធារណៈ និងឯកជនទាំងអស់ ធ្វើការនៅផ្ទះ តាមប្រព័ន្ធអនឡាញដោយមិនចាំបាច់មកធ្វើការ ផ្ទាល់នោះទេ ដោយទុកអ្នកមកធ្វើការផ្ទាល់ក្នុងមួយស្ថាប័ន ឬក្រុមហ៊ុនមានត្រឹម ១០% តែប៉ុណ្ណោះ"។






ស្ថិតក្នុងបរិបទសម័យកាលជំងឺកូវីដ-១៩ ដ៏លំបាកនេះ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បើទោះបីជាមានផលលំបាកមួយចំនួនយ៉ាងណាក៏ដោយ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៅតែខិតខំបន្តដឹកនាំមន្ត្រីបុគ្គលិកក្នុងស្ថាប័នឲ្យបំពេញការងារបម្រើសេវាជូនសមាជិករបស់ខ្លួន ប្រកបដោយទំនួលខុសត្រូវខ្ពស់ និងភាពទាន់ពេលវេលា ជូនដល់សមាជិករបស់ខ្លួន។

ក្រៅពីកិច្ចការដែលបានបំពេញដ៏សំខាន់នៅក្នុងស្ថាប័នរបស់ខ្លួន នៅថ្ងៃព្រហស្បតិ៍ ទី២៥ ខែមីនា ឆ្នាំ២០២១ នេះ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម បានអញ្ជើញធ្វើបាឋកថាជូនដល់សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១១ សិស្សមន្ត្រីក្រមការជំនាន់ទី៩ និងកម្មសិក្សាការីទាំងអស់ នៃសាលាភូមិន្ទរដ្ឋបាល ដោយក្នុងនោះ ក៏មានវត្តមានចូលរួមពីសំណាក់ **ឯកឧត្តម យក់ប៊ុនណា** រដ្ឋលេខាធិការប្រចាំការនៃក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល តាមរយៈប្រព័ន្ធវីដេអូ(Video Conference) ក្រោមប្រធានបទ"តួនាទី និងភារកិច្ចរបស់បេឡាជាតិសន្តិសុខសង្គម" ដ៏សំខាន់មួយនេះផងដែរ។

បទបង្ហាញនេះ មានសារៈសំខាន់ណាស់ក្នុងការបញ្ជ្រាបការយល់ដឹងទៅកាន់សិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការ និងកម្មសិក្សាការីទាំងអស់ នៃសាលាភូមិន្ទរដ្ឋបាល ស្តីអំពីបេសកកម្មរបស់ ប.ស.ស. ដើម្បីយកទៅផ្សព្វផ្សាយបន្ត ក្នុងន័យលើកកម្ពស់ការផ្តល់សេវាគាំពារសង្គម ដើម្បីធានាឲ្យមានសមធម៌ និងសាមគ្គីធម៌សង្គម និងដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ ក្នុងគ្រាបច្ចុប្បន្នដែលជំងឺកូវីដ-១៩ នៅតែបន្តវាយលុកមិនទាន់ចប់នៅឡើយ ។

សូមបញ្ជាក់ថា បទបង្ហាញនេះធ្វើឡើងពេញមួយព្រឹកនៅសាលប្រជុំ ប.ស.ស. រាជធានីភ្នំពេញ តាមរយៈប្រព័ន្ធវីដេអូ (Video Conference)៕











# ឯកឧត្តម អ៊ុក សមវិទ្យា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៅតែខិតខំបន្តដឹកនាំមន្ត្រីបុគ្គលិកក្នុងស្ថាប័នឲ្យបំពេញការងារបម្រើសេវាជូនសមាជិករបស់ខ្លួនប្រកបដោយទំនួលខុសត្រូវខ្ពស់



មកដល់ខែឧសភា ឆ្នាំ២០២១ នេះ ជំងឺកូវីដ-១៩ នៅតែបន្តគំរាមកំហែងដល់អាយុជីវិតពលរដ្ឋនៅទូទាំងពិភពលោកដែលគួរឲ្យភ័យខ្លាចបំផុត បើទោះបីវ៉ាក់-សាំងចាក់ការពារត្រូវបានរកឃើញ និងកំពុងបន្តចាក់ជូនពលរដ្ឋរបស់ខ្លួន នៅបណ្តាប្រទេសជាច្រើនហើយក៏ដោយ។

ព្រះរាជាណាចក្រកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃបំផុតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខដឹកនាំនៃព្រះរាជាណាចក្រកម្ពុជា បានគិតគូរខ្ពស់បំផុតពីសុខុមាលភាពរបស់













មន្ត្រីរាជការ បុគ្គលិកគ្រប់ស្ថាប័នរបស់រដ្ឋ និងឯកជន រួមទាំងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងបងប្អូនប្រជាពលរដ្ឋនៅក្នុងប្រទេសទាំងមូលផងដែរ។ ជាមួយនឹងការដាក់ចេញនូវផែនការយ៉ាងហ្មត់ចត់ក្នុងការទប់ស្កាត់នូវការរីករាលដាលនៃជំងឺកូវីដ-១៩ តាមរយៈវិធានការសុខាភិបាល ៣ការពារ និង ៣កុំ។

ទន្ទឹមគ្នានឹងស្ថានភាពនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅតែបន្តអូសបន្លាយ ដែលបង្កឲ្យមានផលប៉ះពាល់ទៅដល់សេដ្ឋកិច្ចពិភពលោកយ៉ាងធ្ងន់ធ្ងរ រួមទាំងប្រទេសកម្ពុជាយើងផងដែរនោះ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានក្រើនរំលឹក និងណែនាំដល់មន្ត្រី បុគ្គលិកក្នុងស្ថាប័នក្រោមឱវាទទាំងអស់ជាមួយនឹងកិច្ចការរបស់ខ្លួនត្រូវបំពេញការងារយ៉ាងហ្មត់ចត់ប្រកបដោយភាពទទួលខុសត្រូវខ្ពស់ ដើម្បីផ្តល់សេវារបបសន្តិសុខសង្គមជូនបងប្អូនកម្មករនិយោជិតជាសមាជិក ប.ស.ស. បានទាន់ពេលវេលា បើទោះបីកន្លងមកនេះ មន្ត្រី និងបុគ្គលិកជំនាញទាំងអស់ បានបំពេញកិច្ចការរបស់ខ្លួនទទួលបានលទ្ធផលល្អប្រសើរយ៉ាងណាក្តី ក៏កុំភ្លេចត្រូវចូលរួមទប់ស្កាត់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយអនុវត្តតាមវិធានសុខាភិបាល ដែលបានដាក់ចេញ។

សូមបញ្ជាក់ថា ការផ្តល់ឱវាទណែនាំដល់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកខាងលើ ត្រូវបានប្រព្រឹត្តទៅនាថ្ងៃពុធ ទី២៦ ខែឧសភា ឆ្នាំ២០២១ នៅសាលប្រជុំធំ ប.ស.ស. រាជធានីភ្នំពេញ ដោយមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក ប.ស.ស. សរុបប្រមាណជិត ១០០នាក់ តាមរយៈប្រព័ន្ធវីដេអូ (VideoConference)៕










# ឯកឧត្តម អ៊ុក សមវិទ្យា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក ប.ស.ស. ផ្តល់កិត្តិយសអញ្ជើញចូលរួមប្រជុំពិភាក្សាស្តីពី "ការធ្វើបច្ចុប្បន្នភាពលើវឌ្ឍនភាពការងារ និងផែនការការងារបន្តរវាងបេឡាជាតិសន្តិសុខសង្គម និងអង្គការអន្តរជាតិខាងការងារ (ILO)

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ក្នុងកិច្ចប្រជុំពិភាក្សា នាថ្ងៃចន្ទ ទី៧ ខែមិថុនា ឆ្នាំ២០២១ នេះបានថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ ដល់អង្គការអន្តរជាតិខាងការងារ (ILO) ដែលកន្លងមក ក៏ដូចជាពេលបច្ចុប្បន្ននេះនៅតែផ្តល់ការជួយជ្រោមជ្រែងគាំទ្រដល់ ប.ស.ស. ទាំងផ្នែកបច្ចេកទេស ការបណ្តុះ-បណ្តាលទៅលើផ្នែកធនធានមនុស្ស រួមទាំងផ្នែកហិរញ្ញវត្ថុជាដើម ដែលបង្ហាញឲ្យឃើញអំពីការបង្កើនកិច្ចសហប្រតិបត្តិការរវាង ប.ស.ស. ជាមួយនឹងអង្គការអន្តរជាតិខាងការងារ (ILO) កាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ក្នុងការបំពេញការងារជាមួយគ្នា ប្រកបដោយនិរន្តរភាពនិងជោគជ័យបន្ថែមទៀតនាពេលខាងមុខ។








**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងឡើងថា កិច្ចប្រជុំនេះ គឺជាកិច្ចពិភាក្សាដ៏សំខាន់មួយ ដែលផ្តោតទៅលើចំនួន ៧ចំណុច រួមមានជាអាទិ៍៖

១.គម្រោងស្តីពី ការសិក្សានិងការវាយតម្លៃរបបធានារ៉ាប់រងសុខភាពនៃ ប.ស.ស.

២.ការសិក្សាស្រាវជ្រាវអំពី "អនុលោមភាព នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម"

៣.ការគាំទ្រលើយុទ្ធនាការផ្សព្វផ្សាយអំពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិត

៤.វគ្គបណ្តុះបណ្តាលស្តីពី គោលការណ៍ណែនាំ នៃអភិបាលកិច្ចល្អ របស់សមាគមសន្តិសុខសង្គមអន្តរជាតិ (ISSA)

៥.ការគាំទ្រសម្រាប់ការអភិវឌ្ឍសមត្ថភាពផ្នែកវាយតម្លៃហានិភ័យហិរញ្ញវត្ថុនិងផ្នែកវិនិយោគមូលនិធិសន្តិសុខសង្គមនៃ ប.ស.ស.

៦.ការធ្វើបទបង្ហាញស្តីពី "ផែនការលម្អិតផ្នែកអភិវឌ្ឍន៍ករណីប្រតិបត្តិការនៃគម្រោងទំនើបភាវូបនីយកម្ម"

៧.ការអនុវត្តគម្រោងទំនើបភាវូបនីយកម្មដំណាក់កាលទី២

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបញ្ជាក់ទៀតថា កិច្ចប្រជុំពិភាក្សានេះ គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការឈ្វេងយល់អំពីគ្នាឲ្យកាន់តែស៊ីជម្រៅទៅលើកិច្ចសហប្រតិបត្តិការរវាង ប.ស.ស. ជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ដែលកន្លងមក ប.ស.ស. និងអង្គការអន្តរជាតិខាងការងារ (ILO) បានបំពេញការងារជាមួយគ្នាយ៉ាងច្រើនទៅលើវិស័យគាំពារសង្គមកម្ពុជា ក៏ដូចជារបបសន្តិសុខសង្គមដោយទទួលបានលទ្ធផលល្អយ៉ាងគាប់ប្រសើរ ឆ្លើយតបទៅនឹងគោលនយោបាយជាតិគាំពារសង្គមដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សូមបញ្ជាក់ថា កិច្ចប្រជុំពិភាក្សាការងារខាងលើ ត្រូវបានរៀបចំឡើងនៅសាលប្រជុំធំនៃ ប.ស.ស. ស្នាក់ការកណ្តាលរាជធានីភ្នំពេញ ដោយមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសជំនាញនៃ ប.ស.ស. រួមទាំងថ្នាក់ដឹកនាំរបស់អង្គការអន្តរជាតិខាងការងារ (ILO) សរុបប្រមាណជាង ១០នាក់៕












# ប.ស.ស. កម្ពុជា ចូលរួមមហាសន្និបាតលើកទី៥ នៃសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី

មហាសន្និបាតលើកទី៥ នៃសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA) ត្រូវបានរៀបចំឡើងដោយអង្គភាពCOM-WEL នៃសាធារណរដ្ឋកូរ៉េ និងជាប្រធានសមាគម (AWCA) ក្នុងអាណត្តិឆ្នាំ២០២០-២០២១ ដោយមានការចូលរួមពីស្ថាប័នសន្តិសុខសង្គមចំនួន ១៣អង្គភាព មកពីបណ្តាប្រទេសចំនួន១០ ដែលក្នុងនោះសម្រាប់ ប.ស.ស. កម្ពុជា ក៏បានផ្តល់កិត្តិយសពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA) បានដឹកនាំគណៈប្រតិភូ និងមន្ត្រីបច្ចេកទេសជំនាញ នៃ ប.ស.ស. មួយចំនួនចូលរួមនាថ្ងៃសុក្រ ទី១៨ ខែមិថុនា ឆ្នាំ២០២១។

**ឯកឧត្តម** KANG Soonhie ប្រធានអង្គភាព COMWEL នៃសាធារណៈរដ្ឋកូរ៉េ និងជាប្រធានសមាគម (AWCA) អាណត្តិឆ្នាំ២០២០-២០២១ ក្នុងឱកាសថ្លែងបើកនៃមហាសន្និបាតលើកទី៥នេះ **ឯកឧត្តម** បានបញ្ជាក់ថា វាពិតជាគួរឲ្យសោកស្តាយខ្លាំងណាស់ ដែលយើងត្រូវបង្ខំឲ្យមានការរៀបចំមហាសន្និបាតនេះឡើង តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting) ហើយនេះក៏ដោយសារតែជំងឺកូវីដ-១៩ នៅតែបន្តការគំរាមកំហែង និងអូសបន្លាយមិនទាន់ផុតរលត់នៅឡើយ ក៏ប៉ុន្តែទោះយ៉ាងណា នៅពេលកម្មវិធីយុទ្ធនាការចាក់វ៉ាក់សាំងនៅជុំវិញពិភពលោកបានដំណើរការយ៉ាងរលូន ខ្ញុំជឿជាក់ថា យើងនឹងអាចជួបពិភាក្សាយ៉ាងកក់ក្តៅជាមួយគ្នាដោយផ្ទាល់ និងចែករំលែកចំណេះដឹង រួមទាំងបទពិសោធន៍ល្អៗ ដើម្បីអនុវត្តជាមួយគ្នា











ទៅវិញទៅមក ក្នុងការទទួលបានលទ្ធផលល្អគាប់ប្រសើរ ដើម្បីពង្រីកកិច្ចសហការ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាសមាជិកនៃសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី(AWCA)។

បន្ទាប់ពីថ្លែងសុន្ទរកថាបើក នៃមហាសន្និបាតលើកទី៥ ពីសំណាក់ប្រធានអង្គភាព COMWEL នៃសាធារណរដ្ឋកូរ៉េ និងជាប្រធានសមាគម (AWCA) **ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. និងជាអនុប្រធានសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA) ក៏បានថ្លែងបញ្ជាក់ឲ្យដឹងដែរថា មហាសន្និបាតនេះ គឺធ្វើឡើងជារៀងរាល់ ២ឆ្នាំម្តង ដើម្បីពិនិត្យ និងពិភាក្សាឡើងវិញនូវប្រសិទ្ធភាពការងារ និងលទ្ធផលសម្រេចបានកន្លងមករបស់សមាជិកនៃសមាគម តាមរយៈការចែករំលែកចំណេះដឹង និងផ្លាស់ប្តូរបទពិសោធន៍នៃការអនុវត្តជាមួយគ្នាទៅវិញទៅមកក្នុងការទទួលបានផលប្រយោជន៍រួម ដើម្បីពង្រីកកិច្ចសហការ និងពង្រឹងកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួតជាមួយបណ្តាសមាជិក នៃសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA) សម្រាប់អនុវត្តសំណងគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត ស្របតាមបរិបទនៃប្រទេសនីមួយៗក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។



**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបន្តទៀតថា មហាសន្និបាតលើកទី៥ នៃសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA) ដែលបានប្រារព្ធឡើងពេញមួយរសៀលនេះ បានលើកយកចំណុចសំខាន់ៗមួយចំនួន ដើម្បីពិនិត្យ និងពិភាក្សារួមគ្នា ដូចជា៖

១.របាយការណ៍អំពីសកម្មភាព និងលទ្ធផលសម្រេចបានរបស់សមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA) ឆ្នាំ២០១៩-២០២១

២.ការអនុម័តលើការកែសម្រួល "ប្រការ" នៃសេចក្តីថ្លែងការណ៍របស់សមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី(AWCA)

៣.ការអនុម័តលើសេចក្តីថ្លែងការណ៍រួមថ្មីរបស់សមាគម សំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA)

៤.ការអនុម័តលើគោលការណ៍ណែនាំសម្រាប់គណៈកម្មការបច្ចេកទេសរបស់សមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA)

៥.ការបោះឆ្នោតជ្រើសតាំង លោក Mohammed Azman Aziz នាយកប្រតិបត្តិនៃអង្គភាពសន្តិសុខសង្គម (SOCSO) នៃប្រទេសម៉ាឡេស៊ី ជាប្រធានក្នុងអាណត្តិ ២០២២-២០២៣ នៃសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA)

៦.ផែនការសកម្មភាពឆ្នាំ២០២២-២០២៣ នៃសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA)។

គួរឲ្យដឹងផងដែរថា សមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (Asian Workers' Compensation Association, (AWCA)) ត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ២០១២ ក្នុងគោលបំណងដើម្បីអភិវឌ្ឍសំណងគ្រោះថ្នាក់ការងារ ឬរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារនៅក្នុងបណ្តាប្រទេសនៅតំបន់អាស៊ី សម្របសម្រួលឲ្យមានការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការនៅក្នុងរបបដូចគ្នា ក៏ដូចជាបង្កើនអត្ថប្រយោជន៍រួមក្នុងបណ្តាប្រទេសជាសមាជិកទាំង ១០រួមមាន ថៃ វៀតណាម ស្រីលង្កា កូរ៉េ ហ្វីលីពីន ម៉ុងហ្គោលី ម៉ាឡេស៊ី ឡាវ ឥណ្ឌូនេស៊ី រួមទាំងកម្ពុជាយើងផងដែរ។












# ប.ស.ស. កម្ពុជាចូលរួមសន្និសីទសកលស្តីពី “ការធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចនៃប្រព័ន្ធគាំពារសង្គម ដើម្បីឆ្ពោះទៅកិច្ចគាំពារសង្គមជាសកល”

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គមកម្ពុជា នាថ្ងៃចន្ទ ទី២៨ ខែមិថុនា ឆ្នាំ២០២១ បានដឹកនាំមន្ត្រីបច្ចេកទេសជំនាញមួយចំនួន ចូលរួមសន្និសីទសកលស្តីពី “ការធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចនៃប្រព័ន្ធគាំពារសង្គមដើម្បីឆ្ពោះទៅរកកិច្ចគាំពារសង្គមជាសកល” តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting) ដែលរៀបចំដោយ ILO-UNDESA-CHINA។

គួរឲ្យដឹងដែរថា ILOUNDESA-CHANA កន្លងមកបានគាំទ្រនូវគម្រោងទំនើបភាវូបនីយកម្មរបស់ ប.ស.ស. ដោយបានបញ្ចប់ដំណាក់កាលទី១ នៃគម្រោងដែលបានជួយសម្រួលដល់ ប.ស.ស. កម្ពុជា ទៅលើកិច្ចការមួយចំនួនរួមមានការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះ-បណ្តាល ការរក្សាបុគ្គលិកជំនាញប្រកបដោយសក្តានុពល ការធ្វើសមាហរណកម្មប្រព័ន្ធ ICT ដោយធ្វើការកែតម្រូវព័ត៌មានគ្រប់គ្រងរបាយការណ៍ និងការត្រួតពិនិត្យតាមដានប្រតិបត្តិការជាដើម ហើយសម្រាប់ជាជំហានបន្ទាប់ ប.ស.ស. នឹងបន្តអនុវត្តគម្រោងទំនើបភាវូបនីយកម្មដំណាក់កាលទី២ របស់ខ្លួន ដើម្បីអនុវត្តដំណើរការថ្មីតាមប្រព័ន្ធឌីជីថល ការអភិវឌ្ឍប្រព័ន្ធ ICT សមត្ថភាពធនធានមនុស្ស និងសមត្ថភាពផ្សេងទៀត ដែលបានកំណត់នៅក្នុងគំរូប្រតិបត្តិការជាគោលដៅ ដែលគម្រោងនេះ បានបង្កើតឡើងដំបូងក្នុងឆ្នាំ២០១៩ និងត្រូវបញ្ចប់ក្នុងបំណាច់ឆ្នាំ២០២១។







សន្និសីទជាសកលខាងលើនេះដែរ បានផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១.ការពង្រឹងប្រព័ន្ធគាំពារសង្គម ដើម្បីពង្រីកកិច្ចគាំពារសង្គមជាសកល

២.ការសិក្សាឈ្វេងយល់ពីទស្សនៈ និងបទពិសោធន៍ នៃការពង្រឹងអភិបាល-កិច្ច នៃប្រព័ន្ធគាំពារសង្គម

៣.ការធ្វើបទបង្ហាញ អំពីករណីសិក្សាស្តីពី ទំនើបភាវូបនីយកម្មនៃ ប.ស.ស.

៤.ការធ្វើបទបង្ហាញស្តីពី ការពង្រីកកិច្ចគាំពារសង្គមដល់អ្នកបម្រើក្នុងផ្ទះ

៥.ការពិភាក្សាអំពីគំនិតផ្តួចផ្តើមនៅក្នុងការកសាងប្រព័ន្ធសន្តិសុខសង្គមឲ្យបានកាន់តែល្អប្រសើរ។

សូមបញ្ជាក់ថា សន្និសីទសកលនេះ មានការអញ្ជើញចូលរួមពី តំណាងក្រសួងធនធានមនុស្ស និងសន្តិសុខសង្គម នៃសាធារណរដ្ឋប្រជាមានិតចិន តំណាងអង្គភាពសន្តិសុខសង្គម នៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន តំណាង UNDESA និងជំនាញការ នៃក្រុមហ៊ុន Development Pathways ជំនាញការអង្គការអន្តរជាតិខាងការងារ (ILO) តំណាងសមាគមសន្តិ-សុខសង្គមអន្តរជាតិ (ISSA) តំណាងសង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវ ដៃគូពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា រួមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ប.ស.ស. មួយចំនួនផងដែរ៕













# អគ្គនាយក បេឡាជាតិសន្តិសុខសង្គម ធ្វើបទបង្ហាញស្តីពីលទ្ធផល នៃការសិក្សាគណនា លើការព្យាករណ៍បន្ទុកចំណាយ ផ្នែកប្រាក់សោធន សម្រាប់មន្ត្រីរាជការស៊ីវិល

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នាថ្ងៃអង្គារ ទី១៣ ខែកក្កដា ឆ្នាំ២០២១ បានផ្តល់កិត្តិយសធ្វើបទបង្ហាញស្តីពី លទ្ធផលនៃការសិក្សាគណនាលើការព្យាករណ៍បន្ទុកចំណាយផ្នែកប្រាក់សោធនសម្រាប់មន្ត្រីរាជការស៊ីវិលឆ្លើយតបទៅ នឹងសំណូមពរចាំបាច់ ពីអគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលបានស្នើឡើងនាពេលថ្មីៗកន្លងមកនេះ តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting)។














នៅក្នុងសាលប្រជុំ ប.ស.ស. **ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម បានធ្វើបទបង្ហាញទាក់ទងទៅតាមគោលការណ៍នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ដោយបានធ្វើការសិក្សាគណនាលើការព្យាករណ៍បន្ទុកចំណាយផ្ទៃប្រាក់សោធន សម្រាប់មន្ត្រីរាជការស៊ីវិលដែលប្រព្រឹត្តទៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម លើកទី៦ កាលពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ កន្លងមក។

សូមបញ្ជាក់ថា ការធ្វើបទបង្ហាញនេះមានការចូលរួមពីថ្នាក់ដឹកនាំក្រុមប្រឹក្សាជាតិគាំពារសង្គម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងថ្នាក់ដឹកនាំបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៕











# ក្នុងបរិបទដ៏លំបាក នៃសម័យកាលជំងឺកូវីដ-១៩ ឯកឧត្តម អ៊ុក សមវិទ្យា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៅតែខិតខំបន្តដឹកនាំមន្ត្រីបុគ្គលិកក្នុងស្ថាប័នឲ្យបំពេញការងារ បម្រើសេវាជូនសមាជិករបស់ខ្លួន ប្រកបដោយទំនួលខុសត្រូវខ្ពស់

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានក្រើនរំលឹក និងណែនាំដល់ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រី និងបុគ្គលិកក្នុងស្ថាប័នក្រោមឱវាទទាំងអស់ ជាមួយនឹងកិច្ចការរបស់ខ្លួន ត្រូវបំពេញការងារយ៉ាងហ្មត់ចត់ប្រកបដោយភាពទទួលខុសត្រូវខ្ពស់ ដើម្បីផ្តល់សេវារបបសន្តិសុខសង្គមជូនបងប្អូនកម្មករនិយោជិតជាសមាជិក ប.ស.ស. បានទាន់ពេលវេលា។

ការផ្តល់ឱវាទណែនាំ ដល់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកខាងលើ ប្រព្រឹត្តទៅនាថ្ងៃព្រហស្បតិ៍ ទី១៥ ខែកក្កដា ឆ្នាំ២០២១ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ ព្រមទាំងលោក លោកស្រីដែលជាប្រធាន អនុប្រធាន គ្រប់សាខា ប.ស.ស. ខេត្ត-ខណ្ឌ ទាំងអស់តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting)។









ជាមួយគ្នានេះ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានមានប្រសាសន៍ទៀតថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជាបានគិតគូរខ្ពស់បំផុតពីសុខុមាលភាពរបស់មន្ត្រីរាជការ បុគ្គលិកគ្រប់ស្ថាប័នរបស់រដ្ឋ និងឯកជន រួមទាំងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងបងប្អូនប្រជាពលរដ្ឋនៅក្នុងប្រទេសទាំងមូលផងដែរ។ ជាមួយគ្នានឹងការដាក់ចេញនូវផែនការយ៉ាងហ្មត់ចត់ក្នុងការទប់ស្កាត់នូវការរីករាលដាលនៃជំងឺកូវីដ-១៩ តាមរយៈវិធានការសុខាភិបាល ៣ការពារ និង ៣កុំ ជាប់ជាប្រចាំ។

ឆ្លើយតបនឹងការអំពាវនាវពីសំណាក់ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តមប្រតិភូ** តែងតែមានការយកចិត្តទុកដាក់ខ្ពស់ និងក្រើនរំលឹកណែនាំដល់មន្ត្រី បុគ្គលិកក្នុងស្ថាប័នក្រោមឱវាទរបស់ខ្លួនឲ្យបង្កើនស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តវិធានការសុខាភិបាលជាមួយគ្នា ព្រមទាំងកិច្ចការរបស់ខ្លួនឲ្យបានហ្មត់ចត់ប្រកបដោយភាពទទួលខុសត្រូវខ្ពស់ ដើម្បីផ្តល់សេវារបបសន្តិសុខ-សង្គមជូនបងប្អូនកម្មករនិយោជិតជាសមាជិក ប.ស.ស. បានទាន់ពេលវេលា បើទោះបីជាកន្លងមកនេះ មន្ត្រី និងបុគ្គលិកជំនាញទាំងអស់ បានបំពេញកិច្ចការរបស់ខ្លួនទទួលបានលទ្ធផលល្អប្រសើរយ៉ាងណាក្តី។

**ឯកឧត្តមប្រតិភូ** បានថ្លែងការកោតសរសើរចំពោះថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រី និងបុគ្គលិក បេឡាជាតិសន្តិសុខសង្គម ដែលកន្លងមក បានអនុវត្ត និងបំពេញការងាររបស់ខ្លួន ទទួលបានលទ្ធ-ផលល្អប្រសើរគួរឲ្យកត់សម្គាល់ បើទោះបីជាស្ថិតក្នុងស្ថានភាពដ៏លំបាក នៃការរីក-រាលដាលជំងឺកូវី-១៩ យ៉ាងណាក៏ដោយ៕











# ប.ស.ស. ចុះអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយធនាគារជាតិនៃកម្ពុជា ស្តីពីកម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស ផ្នែកគ្រប់គ្រងការវិនិយោគ

បេឡាជាតិសន្តិសុខសង្គម(ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអនុស្សរណៈយោគយល់គ្នាស្តីពី កម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស ផ្នែកគ្រប់គ្រងការវិនិយោគ រវាងធនាគារជាតិនៃកម្ពុជា និងបេឡាជាតិសន្តិសុខសង្គម ក្នុងទិសដៅដើម្បីបង្កើតនូវក្របខណ្ឌកិច្ចសហប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជា និងបេឡាជាតិសន្តិសុខសង្គម លើផ្នែកបច្ចេកទេស ក្នុងការជួយអភិវឌ្ឍធនធានមនុស្ស និងពង្រឹងរចនាសម្ព័ន្ធនៃការគ្រប់គ្រងការវិនិយោគមូលនិធិសន្តិ-សុខសង្គមរបស់ ប.ស.ស. តាមរយៈការចែករំលែកចំណេះដឹង និងបទពិសោធន៍របស់មន្ត្រីជំនាញផ្នែកគ្រប់គ្រងការវិនិយោគរបស់ធនាគារជាតិនៃកម្ពុជា សំដៅរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានថ្លែងថាគោលបំណងសំខាន់នៃការចុះអនុស្សរណៈយោគយល់គ្នាគឺជាការផ្តល់ឱកាសឲ្យអង្គភាពទាំងពីរឈ្វេងយល់ពីទស្សនៈផ្សេងៗ ដូចជាការដកស្រង់និងចែករំលែកនូវបទពិសោធន៍ លើបញ្ហាដែលពាក់ព័ន្ធឲ្យគ្នាទៅវិញទៅមក និងបង្កើនកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរឲ្យកាន់តែមានភាពជិតស្និទ្ធ និង







ជាថ្នាលសម្រាប់ពង្រឹងសមត្ថភាព និងចំណេះដឹងផ្នែកគ្រប់គ្រងវិនិយោគរបស់មន្ត្រីបច្ចេកទេសជំនាញ ប.ស.ស. ដើម្បីអនុវត្តការងារវិនិយោគឲ្យកាន់តែមានប្រសិទ្ធភាព និងទទួលបានប្រសិទ្ធផលតាមរយៈឧទាហរណ៍ពិតប្រាកដ និងបទពិសោធន៍ជាក់ស្តែង ដែលបានផ្តល់ផ្ទាល់ដោយដៃគូរបស់ខ្លួន។

**ឯកឧត្តមប្រតិភូ** បានបន្តទៀតថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយសំដៅលើកិច្ចគាំពារសង្គម ក្នុងនោះផ្តោតសំខាន់ទៅលើវិស័យសន្តិសុខសង្គម ដែលមានផ្នែកថែទាំសុខភាពជាចម្បង ហើយកាតព្វកិច្ចនេះតម្រូវឲ្យអង្គភាព ប.ស.ស. ជាអ្នកប្រតិបត្តិផ្ទាល់ទៅលើផ្នែកធំៗចំនួន ៤ គឺ ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន និងផ្នែកនិកម្មភាពការងារ សម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។












**ឯកឧត្តមប្រតិភូ** បានឲ្យដឹងថា បច្ចុប្បន្ន ប.ស.ស. បាននឹងកំពុងអនុវត្តរបបសន្តិសុខសង្គមចំនួន២ គឺផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ហើយនៅពេលដ៏ខ្លីខាងមុខនេះ ប.ស.ស. នឹងដាក់ឲ្យអនុវត្តនូវរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន (ប្រាក់រ៉ឺត្រែត)។ សមាជិក ប.ស.ស. ដែលកំពុងបម្រើការងារក្នុងវិស័យឯកជនទាំងអស់ នឹងទទួលបានប្រាក់សោធននិវត្តន៍ (ប្រាក់រ៉ឺត្រែត) ដូចទៅនឹងមន្ត្រីរាជការផងដែរ។

**ឯកឧត្តមប្រតិភូ** សង្ឃឹមយ៉ាងមុតមាំថា តាមរយៈកិច្ចសហការជាមួយធនាគារជាតិនៃកម្ពុជា នាពេលនេះ ប.ស.ស. នឹងទទួលបានផ្លែផ្កាជាវិជ្ជមាន ដើម្បីរួមចំណែកពង្រឹងការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាលឲ្យកាន់តែទទួលបានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

សូមបញ្ជាក់ថា ពិធីចុះអនុស្សរណៈយោគយល់គ្នាខាងលើនេះ ត្រូវបានរៀបចំឡើងកាលពីថ្ងៃព្រហស្បតិ៍ ទី២៩ ខែកក្កដា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting) ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. និង**លោកជំទាវ ជា សិរី** ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា ព្រមទាំងមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃអង្គភាពស្ថាប័នទាំងពីរសរុប១៤នាក់៕











# ប.ស.ស. បាននឹងកំពុងពន្លឿនការអភិវឌ្ឍមជ្ឈមណ្ឌលព័ត៌មាន ឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃសមាជិករបស់ខ្លួន

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៅថ្ងៃព្រហស្បតិ៍ ទី១៩ ខែសីហា ឆ្នាំ២០២១ បានផ្តល់កិត្តិយសអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិភាក្សា ស្តីពីការអភិវឌ្ឍមជ្ឈមណ្ឌលព័ត៌មាននៃ ប.ស.ស. ដែលកន្លងមកកិច្ចប្រជុំពិភាក្សាទាក់ទងទៅនឹងការអភិវឌ្ឍមជ្ឈមណ្ឌលព័ត៌មាននៃ ប.ស.ស. បានប្រព្រឹត្តទៅជាច្រើនលើករួចមកហើយ។

ក្នុងកិច្ចប្រជុំពិភាក្សាខាងលើនេះ **ឯកឧត្តមប្រតិភូ** បានថ្លែងថា បច្ចុប្បន្នប្រព័ន្ធផ្តល់ព័ត៌មាន (Hotline) ប.ស.ស. គឺជាប្រព័ន្ធធម្មតា ដែលឆ្លើយតបជាសំឡេងអន្តរកម្ម (Interactive Voice Response) ដោយមិនទាន់មានលក្ខណៈទូលំទូលាយឆ្លើយតបតាមតម្រូវការចាំបាច់ របស់សមាជិក ប.ស.ស. បានទាន់ពេលវេលានៅឡើយ។ ដូច្នេះដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាពក្នុងការផ្តល់ព័ត៌មាន បច្ចុប្បន្ន ប.ស.ស. បាននឹងកំពុងបន្តរៀបចំឲ្យមានប្រព័ន្ធរក្សាទុកទិន្នន័យ (Backup Server) ព្រមទាំងសិក្សារៀបចំតបណ្តាញទូរស័ព្ទបន្ថែមទៀត។








**ឯកឧត្តមប្រតិភូ** បានបញ្ជាក់ទៀតថា ការអភិវឌ្ឍមជ្ឈមណ្ឌលផ្តល់ព័ត៌មាន ប.ស.ស. លើប្រព័ន្ធផ្តល់ព័ត៌មាន (Hotline) លេខ ១២៨៦ ដែល ប.ស.ស. បាននឹងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន កំពុងត្រូវបានសិក្សា និងអភិវឌ្ឍន៍កម្មវិធីថ្មី ដើម្បីឲ្យក្លាយជាមជ្ឈមណ្ឌលផ្តល់ព័ត៌មានពេញលេញមួយដែលមានលក្ខណៈស្តង់ដា ប្រកបដោយប្រសិទ្ធភាពខ្ពស់។

មួយវិញទៀតបច្ចុប្បន្ន ប.ស.ស. ក៏បានបង្កើតកម្មវិធីទូរស័ព្ទដៃដែលមានឈ្មោះថា "NSSF Member App" ដំណើរការទាំងប្រព័ន្ធប្រតិបត្តិការ Android និង IOS ដែលកម្មវិធីទូរស័ព្ទដៃមួយនេះត្រូវបានបង្កើតឡើង ដើម្បីផ្តល់ភាពងាយស្រួល និងអនុញ្ញាតឲ្យសមាជិក ប.ស.ស. ទាំងអស់អាចចូលទៅពិនិត្យមើលព័ត៌មានផ្ទាល់ខ្លួន ពិនិត្យមើលសុពលភាពប័ណ្ណសមាជិក ប.ស.ស. របស់ខ្លួន, ពិនិត្យមើលប្រវត្តិនៃការបង់ភាគទាន, ពិនិត្យមើលព័ត៌មាននៃការចូលប្រើប្រាស់សេវានៅតាមមូលដ្ឋានសុខាភិបាលដែលជាដៃគូ ប.ស.ស. និងអាចពិនិត្យមើលព័ត៌មានផ្សេងៗជាច្រើនទៀត បានគ្រប់ពេលវេលាគ្រប់ទីកន្លែង។

**ឯកឧត្តមប្រតិភូ** ក៏បានវាយតម្លៃខ្ពស់ផងដែរ ចំពោះអង្គការអន្តរជាតិ និងអង្គភាពពាក់ព័ន្ធនានា ពិសេសអង្គការហ្គ្រេត (GRET) កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) និងអង្គការអន្តរជាតិខាងការងារ (ILO) ដែលតែងតែផ្តល់ការគាំទ្រមកលើ ប.ស.ស. ទាំងការងារបច្ចេកទេស ទាំងផ្នែកធនធានមនុស្ស និងផ្នែកហិរញ្ញវត្ថុជាដើម ក្នុងការចូលរួមអភិវឌ្ឍវិស័យសន្តិសុខសង្គមកម្ពុជាឲ្យកាន់តែមានភាពល្អប្រសើរឡើង។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំពិភាក្សាខាងលើ ប្រព្រឹត្តទៅនៅសាលប្រជុំនៃ ប.ស.ស. ស្នាក់ការកណ្តាលរាជធានីភ្នំពេញ ដោយមានវត្តមានចូលរួមពីមន្ត្រីបច្ចេកទេសជំនាញ និងអ្នកជំនាញការរបស់ ប.ស.ស. រួមទាំងតំណាងអង្គការហ្គ្រេត (GRET) និងតំណាង GIZ មួយចំនួនផងដែរ។










# ក្រុមការងារបច្ចេកទេសនៃ ប.ស.ស. ជួបពិភាក្សាការងារ ជាមួយតំណាងក្រសួងកិច្ចការនារី

នៅថ្ងៃចន្ទ ទី១២ ខែមេសា ឆ្នាំ២០២១ **ឯកឧត្តមបណ្ឌិត ស៊ុំ សោភ័ណ** អគ្គនាយករង ប.ស.ស. ដោយមានការអនុញ្ញាតពី **ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. បានដឹកនាំក្រុមការងារបច្ចេកទេសរបស់ខ្លួនជួបពិភាក្សាការងារជាមួយតំណាងក្រសួងកិច្ចការនារី នៅសាលប្រជុំធំនៃបេឡាជាតិសន្តិសុខសង្គម ប.ស.ស. តាមរយៈប្រព័ន្ធវីដេអូ (Video Conference)។

**ឯកឧត្តមអគ្គនាយករង** បានបញ្ជាក់ឲ្យដឹងថា ជំនួបពិភាក្សាខាងលើនេះផ្តោតសំខាន់ទៅលើចំណុចធំៗមួយចំនួនដូចជា៖

- កិច្ចសហប្រតិបត្តិការរវាង ប.ស.ស. និងក្រសួងកិច្ចការនារី លើការអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជាក្រោមកិច្ចសហ-ប្រតិបត្តិការអូស្ត្រាលី-កម្ពុជា(ACCESS)
- ការលើកកម្ពស់វិស័យយេនឌ័រសម្រាប់ការផ្តល់ឱកាសការងារចំពោះស្ត្រីជាអាទិភាព
- ផលប៉ះពាល់ និងអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតក្នុងវិស័យកាត់ដេរ ជាពិសេសបងប្អូនកម្មករនិយោជិតជាស្ត្រី អំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ និងការបើកប្រាក់ឧបត្ថម្ភសម្រាប់កម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ដែលបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតី នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល
- កិច្ចដំណើរការ នៃការផ្សព្វផ្សាយ និងការបញ្ជ្រាបព័ត៌មាន នៃការអនុវត្តរបបសន្តិសុខសង្គម ជូនដល់សមាជិក ប.ស.ស. អំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩៕





# វគ្គបណ្តុះបណ្តាលស្តីពី "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន" ជូនដល់ថ្នាក់ដឹកនាំ គ្រប់សាខា ប.ស.ស. ខេត្ត/ខណ្ឌ នៃ ប.ស.ស.

**ឯកឧត្តម ម៉េង ហុង** អគ្គនាយករងបេឡាជាតិសន្តិសុខសង្គម តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នាថ្ងៃព្រហស្បតិ៍ ទី២៧ ខែឧសភា ឆ្នាំ២០២១ បានអញ្ជើញបើកវគ្គបណ្តុះបណ្តាលស្តីពី "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន" តាមរយៈប្រព័ន្ធវីដេអូ (Video Conference) ជូនដល់ថ្នាក់ដឹកនាំ គ្រប់សាខា ប.ស.ស. ខេត្ត/ខណ្ឌ។















ថ្លែងនាឱកាសបើកវគ្គបណ្តុះបណ្តាលនេះដែរ **ឯកឧត្តមអគ្គនាយករង** បានមានប្រសាសន៍ថា នេះជាវគ្គបណ្តុះបណ្តាលលើកទី៣ហើយ ដូចនេះថ្នាក់ដឹកនាំគ្រប់សាខា ប.ស.ស. ខេត្ត/ខណ្ឌ ទាំងអស់ត្រូវតែយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពដោយស្មារតីទទួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់ ក្នុងការផ្តល់សេវារបបសន្តិសុខសង្គម ជូនបងប្អូនដែលជាសមាជិករបស់ខ្លួន ជាពិសេសឈ្វេងយល់ឲ្យបានកាន់តែច្បាស់ តាមរយៈវគ្គបណ្តុះបណ្តាលនេះ ដើម្បីយកទៅអភិវឌ្ឍន៍លើការងារកាន់តែប្រសើរ និងប្រកបដោយភាពច្នៃប្រឌិត ព្រមទាំងបន្តចែករំលែកចំណេះដឹងទៅដល់មន្ត្រី និងបុគ្គលិករបស់ខ្លួនឲ្យកាន់តែទូលំទូលាយបន្ថែមទៀត ដែលនេះជាមធ្យោបាយដ៏ល្អក្នុងការដោះស្រាយនូវរាល់បញ្ហាប្រឈមនានាឲ្យបានទាន់ពេលវេលា ទៅដល់សហគ្រាសគ្រឹះស្ថាន និងអង្គភាពពាក់ព័ន្ធទាំងអស់ ព្រមទាំងបន្តផ្សព្វផ្សាយទៅកាន់សមាជិករបស់ខ្លួនឲ្យយល់ដឹងកាន់តែច្បាស់ពីអត្ថប្រយោជន៍ដែលពួកគាត់ត្រូវទទួលបានពី ប.ស.ស.។

សូមបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលខាងលើនេះ ត្រូវបានធ្វើបទបង្ហាញដោយ **លោក សុក ម្ញុរ៉ា** ប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គម នៃ ប.ស.ស. ប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ១រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ នៅសាលប្រជុំធំ នៃ ប.ស.ស. ស្នាក់ការកណ្តាល រាជធានីភ្នំពេញ តាមរយៈប្រព័ន្ធវីដេអូ (Video Conference)៕









# ថ្នាក់ដឹកនាំ ប.ស.ស. ចូលរួមកិច្ចពិភាក្សាស៊ីជម្រៅជាមួយក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ នៃទីស្ដីការគណៈរដ្ឋមន្ត្រី

**ឯកឧត្តម ប៉ែន នរៈវុធ** អគ្គនាយករង ប.ស.ស. ដោយទទួលបានការអនុញ្ញាតពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នាថ្ងៃសុក្រ ទី២៥ ខែមិថុនា ឆ្នាំ២០២១ **ឯកឧត្តម** បានដឹកនាំមន្ត្រីជំនាញមួយចំនួនចូលរួមកិច្ចពិភាក្សាស៊ីជម្រៅជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយសហការជាមួយក្រុមប្រឹក្សាជាតិគាំពារសង្គម និងកម្មវិធីស្បៀងអាហារពិភពលោកប្រចាំនៅកម្ពុជា ក្រោមប្រធានបទស្តីពី ការចូលរួមចំណែករបស់ប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង ដើម្បីឆ្លើយតបទៅនឹងគ្រោះអាសន្ន និងវិបត្តិនានា។










កិច្ចប្រជុំពិភាក្សានេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីប្រមូលធាតុចូលសំខាន់ៗសម្រាប់រៀបចំផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងប្រកបដោយចីរភាពនៅកម្ពុជា និងត្រៀមសម្រាប់កិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងពិភពលោកនាពេលខាងមុខ ក្រោមការដឹកនាំសម្របសម្រួលរបស់ **ឯកឧត្តម សុខ ស៊ីឡូ** អគ្គលេខាធិការនៃក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ **ឯកឧត្តម ចន ណារិទ្ធ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិគាំពារសង្គម និង លោកស្រី **Clair Conan** ជានាយកកម្មវិធីស្បៀងអាហារពិភពលោកប្រចាំនៅកម្ពុជា។

សូមបញ្ជាក់ថា កិច្ចប្រជុំពិភាក្សានេះ ត្រូវបានរៀបចំឡើងតាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting) ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនឯកជនដែលពាក់ព័ន្ធក្នុងវិស័យខាងលើមួយចំនួនផងដែរ៕











# សមាជិក ប.ស.ស. ជាកម្មករនិយោជិតនៃវិស័យឯកជន នឹងទទួលបានប្រាក់សោធន (ប្រាក់រ៉ឺត្រែត)

នៅថ្ងៃព្រហស្បតិ៍ ទី៥ ខែសីហា ឆ្នាំ ២០២១ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** អគ្គនាយករង នៃ ប.ស.ស. បានឲ្យដឹងថា សមាជិក ប.ស.ស. ដែលជាកម្មករនិយោជិតនៃវិស័យឯកជនទាំងអស់ នឹងទទួលបានប្រាក់សោធន (ប្រាក់រ៉ឺត្រែត) នៅពេលចូលនិវត្តន៍ដូចទៅនឹងមន្ត្រីរាជការដែរ ពេលដែល ប.ស.ស. ដាក់ឲ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននាពេលឆាប់ៗខាងមុខ។

ការថ្លែងឡើងបែបនេះ ក្នុងឱកាសដែល **ឯកឧត្តម** អញ្ជើញធ្វើបទបង្ហាញ និងពិភាក្សាលើប្រធានបទស្តីពីការលើកកម្ពស់ការយល់ដឹងអំពីការងារសមរម្យ សម្រាប់កម្មករនិយោជិតជាស្ត្រី ដែលធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។



**ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ក៏បានលើកឡើងអំពីវឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គម ដែលក្នុងនោះរួមមាន៖ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដែលមានវិសាលភាពគ្របដណ្តប់លើវិស័យឯកជន និងវិស័យសាធារណៈ រួមទាំងអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដូចមានចែងក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម ពិសេសសម្រាប់ សមាជិក ប.ស.ស. ដែលជាស្ត្រីសម្រាលកូន ទាំងក្នុង និងក្រៅប្រព័ន្ធក៏នឹងកំពុងទទួលបានរបបប្រាក់ឧបត្ថម្ភបន្ថែមពីរាជរដ្ឋាភិបាលកម្ពុជាផងដែរ។

នេះគឺជាការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំ តែងតែគិតគូរខ្ពស់បំផុតអំពីសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត។

សូមបញ្ជាក់ថា កិច្ចប្រជុំខាងលើនេះ ត្រូវបានរៀបចំឡើងដោយ ក្រសួងកិច្ចការនារី តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting) ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីក្របខ័ណ្ឌ និងវិធានការផ្នែកគោលនយោបាយស្តីពីកិច្ចគាំពារសង្គម ដែលផ្តល់អត្ថប្រយោជន៍ដល់ស្ត្រី ជាពិសេសក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយមានការអញ្ជើញចូលរួមពីតំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម តំណាងមន្ទីរកិច្ចការនារីទាំង ២៥រាជធានី/ខេត្ត តំណាងអង្គការ APHEDA អង្គការ Oxfam និងតំណាងសហជីពនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ សរុបប្រមាណជាង ១០០នាក់។








# ក្រុមការងារ ស.ផ.ក នៃ ប.ស.ស. ប្រជុំពិភាក្សា ត្រួតពិនិត្យលើរបាយការណ៍ ស្ដីពីលទ្ធផលការងារ សម្រេចបានក្នុងឆ្នាំ២០២០ និងទិសដៅការងារអនុវត្ត បន្តរបស់ខ្លួន

នៅសាលប្រជុំធំនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) រាជធានីភ្នំពេញ នាថ្ងៃអង្គារ ទី៩ ខែកុម្ភៈ ឆ្នាំ២០២១ មានកិច្ចប្រជុំពិភាក្សាមួយ ស្ដីពីការត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០២០ និងទិសដៅការងារអនុវត្តបន្តរបស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិសន្តិសុខសង្គម ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាក្រោមអធិបតីភាព **ឯកឧត្តម ព្រាប ច័ន្ទវិបុល**
















អនុប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋា-ភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត និងជាសមាជិកគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

បន្ទាប់ពីកិច្ចប្រជុំបានបញ្ចប់ **ឯកឧត្តម ព្រាប ច័ន្ទវិបុល** បានផ្តល់បទសម្ភាសន៍ជាមួយក្រុមការងារព័ត៌មាន ប.ស.ស. ដោយ **ឯកឧត្តម** បានបញ្ជាក់ថា បើប្រៀបធៀបរវាងឆ្នាំ២០២០ ទៅនឹងឆ្នាំ២០១៩ កន្លងទៅ គ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងមកលើបងប្អូនកម្មករនិយោជិត មានការថយចុះរហូត ដល់ទៅ ៣១% ស្មើនឹង ១ ៩០០ករណី ដែលក្នុងនោះ អ្នករងរបួសសរុបចំនួន ៣០% ស្មើនឹង ២ ១៤០នាក់ អ្នកស្លាប់ចំនួន ៤៤% ស្មើនឹង ៨៨នាក់ អ្នករងរបួសធ្ងន់ចំនួន ២៧% ស្មើនឹង ៤០០នាក់, និងអ្នករងរបួសស្រាលចំនួន ៣០% ស្មើនឹង ១ ៦៥២នាក់។

**ឯកឧត្តម** បានបន្ថែមឲ្យដឹងទៀតថា បើទោះបីជាមានការថយចុះនៃករណីគ្រោះថ្នាក់ចរាចរណ៍មកលើបងប្អូនកម្មករនិយោជិតក៏ពិតមែន ក៏ប៉ុន្តែក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងនោះក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃ ប.ស.ស. នៅតែបន្តការសហការគ្នាប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់តាមរយៈ ការរៀបចំលិខិតបទដ្ឋាន ការអប់រំផ្សព្វផ្សាយ និងការបណ្តុះបណ្តាល ដល់អ្នកបើកបររថយន្តដឹកកម្មករ និងកម្មករនិយោជិត អំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដើម្បីអនុវត្តឲ្យបានជោគជ័យនូវផែនការដែលបានគ្រោងទុក ស្របទៅនឹងគោលនយោបាយថ្នាក់ជាតិ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវ-គោករួមចំណែកក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជាឲ្យទទួលបានលទ្ធផលកាន់តែល្អប្រសើរថែមទៀត ក្នុងន័យកាត់បន្ថយចំនួនគ្រោះថ្នាក់ចរាចរណ៍ក៏ដូចជាការស្លាប់ និងរងរបួសដល់កម្មករ ឲ្យថយមកកម្រិតទាបបំផុត។

**ឯកឧត្តម** ក៏បានធ្វើការអំពាវនាវ និងស្នើដល់បងប្អូនអ្នកបើកបររថយន្តដឹកកម្មករ និងបងប្អូនកម្មករនិយោជិតទាំងអស់ ចូលរួមគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឲ្យបានត្រឹមត្រូវ និងចេះយោគយល់អធ្យាស្រ័យគ្នាក្នុងពេលធ្វើដំណើរលើដងផ្លូវ ជាពិសេសអ្នកបើកបររថយន្តដឹកកម្មករមិនត្រូវផ្ទុកចំនួនកម្មករលើសចំណុះ និងចូលរួមផ្លាស់ប្តូរពីការយករថយន្តដឹកទំនិញមកដឹកបងប្អូនកម្មករដោយប្រើប្រាស់រថយន្តដឹកអ្នកដំណើរមកជំនួសវិញ។

សូមបញ្ជាក់ថា៖ កន្លងមក **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម និងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) តែងតែជំរុញក្រុមការងារ ឲ្យបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការចូលរួមផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក សុវត្ថិភាពក្នុងការធ្វើដំណើរគ្រប់រូបភាព ក្នុងន័យចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ដែលធ្លាក់មកលើកម្មករនិយោជិត និងដើម្បីចូលរួមអនុវត្តផែនការសកម្មភាព "សុវត្ថិភាពចរាចរណ៍ផ្លូវគោក ចំពោះកម្មករនិយោជិត" ឲ្យកាន់តែមានប្រសិទ្ធ-ភាពខ្ពស់ ឆ្លើយតបទៅនឹងអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា "ថ្ងៃនេះ ថ្ងៃស្អែកកុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍"៕





# តំណាងអង្គការជាតិ និងអន្តរជាតិ សរុបប្រមាណជាង ១០០ អង្គការ ចូលរួមឈ្វេងយល់ពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

**លោក សុក ប្ញា៉** ប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គម ក្រោមការចាត់តាំងពីសំណាក់ **ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម ប.ស.ស. នាថ្ងៃសុក្រ ទី៧ ខែឧសភា ឆ្នាំ២០២១ បានធ្វើបទបង្ហាញស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជូនដល់តំណាងអង្គការជាតិ និងអន្តរជាតិ សរុបប្រមាណជាង ១០០អង្គការ តាមរយៈប្រព័ន្ធអនឡាញ (Google Meet) ឆ្លើយតបទៅនឹងការស្នើសុំពីតំណាងអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក)។



ក្នុងបទបង្ហាញនេះ **លោក សុក ឫទ្ធី** បានបញ្ជាក់ថា នៅពេលដែលរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនត្រូវបានដាក់ឲ្យដំណើរការ នោះកម្មករនិយោជិត និងបុគ្គលិកក្នុងវិស័យឯកជនទាំងអស់ ទទួលបានប្រាក់សោធន (ប្រាក់រ៉ឺត្រែត) ដូចទៅនឹងមន្ត្រីរាជការដែរ។

**លោក** បានបញ្ជាក់ទៀតថាសម្រាប់ រោងចក្រ សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតដែលបានចុះបញ្ជីរួចរាល់នៅ ប.ស.ស. ក្នុងផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព នោះនឹងក្លាយទៅជាសមាជិក ប.ស.ស. ក្នុងផ្នែកប្រាក់សោធនដោយស្វ័យប្រវត្តិ។

សូមបញ្ជាក់ថា បទបង្ហាញខាងលើប្រព្រឹត្តទៅនៅអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) រាជធានីភ្នំពេញ ដោយមានវត្តមានចូលរួមពីតំណាងអង្គការជាតិ និងអន្តរជាតិ សរុបប្រមាណជិត ១០០ អង្គការតាមរយៈប្រព័ន្ធអនឡាញ (Google Meet)៕











# ដើម្បីឲ្យ ថ្លើមមានសុខភាពល្អ
## អ្នកគួរតែជ្រើសយកអាហារទាំង ៤ មុខនេះមកបរិភោគ

អាហារដែលអាចជួយឲ្យថ្លើមមានសុខភាពល្អ ចេកមានផ្ទុកប៉ូតាស្យូម រហូតដល់ទៅ ៤៧០មីលីក្រាម ដែលជាសារធាតុដ៏ល្អបំផុតសម្រាប់សម្អាតថ្លើម និងបង្កើនកម្រិតប៉ូតាស្យូមនៅក្នុងរាងកាយ។



មើមខ្ញី មានផ្ទុកជាតិសរសៃ ដែលអាចជួយការពារប្រព័ន្ធរំលាយអាហារឲ្យមានសុខភាពល្អ និងកម្ចាត់ជាតិពុលចេញពីរាងកាយដូចផ្លែចេកដែរ។ ខ្ញីមានផ្ទុកសារធាតុអុកស៊ីតកម្ម ដែលអាចជួយពង្រឹងដល់ប្រព័ន្ធភាពស៊ាំ ដើម្បីប្រយុទ្ធប្រឆាំងជាមួយនឹងការឆ្លងមេរោគផ្សេងៗ ។



ជាតិប៉ូតាស្យូមកម្រិតខ្ពស់ ធ្វើឲ្យដំឡូងមានគុណសម្បត្តិជួយសម្អាតថ្លើមយ៉ាងពូកែបំផុត។ ដំឡូងជ្វាមួយមើមមានផ្ទុកជាតិប៉ូតាស្យូម ៧០០មីលីក្រាម រួមទាំងម៉ាញ៉េស្យូម ជាតិដែក វីតាមីនB6 វីតាមីនC និងវីតាមីនD ដែលល្អបំផុតសម្រាប់អ្នកដែលមានជំងឺខ្លាញ់ក្នុងថ្លើម ។

រមៀត គឺជាគ្រឿងទេសដែលមានអត្ថប្រយោជន៍បំផុតសម្រាប់សុខភាព ព្រោះវាមានផ្ទុកសារធាតុប្រឆាំងអុកស៊ីតកម្មអាចការពារបញ្ហារលាក ព្រមទាំងជួយព្យាបាលបញ្ហារំលាយអាហារ។ ជាពិសេសរមៀត អាចជួយឲ្យប្រសើរឡើងនូវមុខងារថ្លើម ក្នុងការកម្ចាត់ជាតិពុល។ ដើម្បីជួយឲ្យថ្លើមមានសុខភាពល្អ អ្នកគួរតែបន្ថែមអាហារទាំងអស់នេះនៅក្នុងរបបអាហារជាប្រចាំ៕







# បណ្ដាំ
## អ្នកព្រះឥរិមធ្យាសា អ៊ូ ហៅឧ៉ុយ

កុំដៀលអ្នកស្រែ ត្រកូលឯងខ្មែរ កុំប្រែក្រឡាស់
ក្រឡេកឃើញគុណ ទន់ខ្លួនសំពះ កុំធ្វើអ្នកណាស់
កុំត្មះអ្នកក្រ។

អ្នកកុំភ្លេចគុណ គ្រូលេខនព្វន្ត គ្រូសូត្រអក្សរ
កុំចាប់ដៃទាញ គំនាប់ងក់ក កុំជជែកត
ស្មើមិត្តសម្លាញ់។

វាស្ត្ររត់ចូលជ្រក សាកសួរទៅមក កុំអើឯងអញ
ពាក្យពុំពីរោះ គេកើតមួក្នាញ់ គេដៀលផ្ចាលផ្ចាញ់
អន្តរាយកេរ្តិ៍ឈ្មោះ។

កុំឆ្មើងអាងបុណ្យ ស្រដីឲ្យទន់ ពោលពាក្យពីរោះ
ខ្លួនអ្នកនិងថ្កើង និងឡើងសក្តិយស កុំឆ្លៀតនាំឈ្លោះ
ញុះញង់អ្នកធំ។

កុំស្អប់អ្នកតូច បើឃើញគ្នាខូច គួរគិតប្រមុំ
ទោសគ្នាតិចតួច ផ្លូចឡើងជាធំ ផ្សែងពួតជាដុំ
ផ្ដុំឆេះជាភ្លើង។

កុំភ្លើនភ្លេចខ្លួន ចេះសាសន៍ចិនយួន កុំចោលខ្មែរយើង
កុំធ្វើក្រអឺត កុំពើតកុំពើង កុំពាក់ស្បែកជើង
ចូលវត្តលោកសង្ឃ។

ដោះមួកដាក់ឆត្រ ឱនកាយប្រតិបត្តិ លំអុតឱនអង្គ
កុំស៊ីតាមឃ្លាន កុំហ៊ានតាមចង់ កាន់ច្បាប់ស្រុកហ្វ្រង់
កុំបង់សាសនា។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ: ៣១៧/២១ អ៦.ប

ថ្ងៃ សុក្រ ១ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០២១

**ជម្រាបមក**

**លោក ហេង សុផាន់ណារិទ្ធ ម្ចាស់អាជីវកម្មព្រឹត្តិបត្រ បេឡាជាតិរបបសន្តិសុខសង្គម**

**កម្មវត្ថុ** ៖ ស្តីពីសំណើសុំការអនុញ្ញាតបន្តសុពលភាពអាជីវកម្មព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម។**

**យោង** ៖-ប្រកាសលេខ៣៥១ព.ម ប្រក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងព័ត៌មាន
-លិខិតលេខ៥០៤ ព.ម ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ របស់ក្រសួងព័ត៌មាន
-ពាក្យស្នើសុំ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់លោក **ហេង សុផាន់ណារិទ្ធ។**

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកជ្រាបថា រដ្ឋបាលរាជធានីភ្នំពេញអនុញ្ញាតឱ្យលោកបន្តដំណើរការអាជីវកម្មព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ដែលមានទីតាំងស្ថិតនៅអាគារលេខ០៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តពីលិខិតលេខ៥០៤ ព.ម ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ របស់ក្រសួងព័ត៌មាន។

ដើម្បីចូលរួមអនុវត្តច្បាប់ ជាពិសេសក្នុងដំណើរការអាជីវកម្មព្រឹត្តិបត្រ រដ្ឋបាលរាជធានីភ្នំពេញស្នើលោក អនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់ ច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា សេចក្តីណែនាំ បទបញ្ជានានាទាក់ទងវិស័យព័ត៌មាន និងសោតទស្សន៍ និងកិច្ចសន្យាអាជីវកម្មព្រឹត្តិបត្រ។

លិខិតអនុញ្ញាតនេះ មានសុពលភាពរយៈពេល ០១(មួយឆ្នាំ) គិតពីថ្ងៃចុះហត្ថលេខាតទៅ ហើយលោកត្រូវស្នើសុំបន្តលិខិតអនុញ្ញាតជាថ្មីឡើងវិញក្នុងរយៈពេល៣០ថ្ងៃមុនលិខិតអនុញ្ញាតនេះផុតសុពលភាព។

ក្នុងករណីលោកមិនអនុវត្តតាមលក្ខខណ្ឌខាងលើ រដ្ឋបាលរាជធានីភ្នំពេញនឹងនិរាករណ៍លិខិតអនុញ្ញាតនេះដោយឥតលក្ខខណ្ឌ។

រដ្ឋបាលរាជធានីភ្នំពេញមានក្តីសង្ឃឹមជឿជាក់លើស្មារតីយកចិត្តទុកដាក់របស់លោក និងអនុវត្តតាមការណែនាំខាងលើដោយការទទួលខុសត្រូវខ្ពស់។

**ជ.អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**
**អភិបាលរង**

**ហួត-ហៃ**

<u>ចម្លងជូន៖</u>
-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌទួលគោក
-មន្ទីរព័ត៌មានរាជធានីភ្នំពេញ
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

# បេឡាជាតិសន្តិសុខសង្គម

**National Social Security Fund**


០២៣ ៨៨ ២៤ ៣៤
០២៣ ៩៩ ៨៤ ១៧
០២៣ ៩៩ ៨៤ ១៨
០២៣ ៩៩ ៨៨ ១៩
០២៣ ៨៨ ២៦ ២៣
១២៨៦ (២៤ម៉ោង/៧ថ្ងៃ)

បេឡាជាតិសន្តិសុខសង្គម
NSSF Official
t.me/nssfcambodia
info@nssf.gov.kh
www.nssf.gov.kh

អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
(បរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)


